ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក ស ក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំខែកក្កដា ឆ្នាំ២០២២ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែកក្កដានេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបាន ២ ១៦០ ១០១ហ.ត ស្មើនឹង៨២,៤៦% នៃផែនការចំនួន ២ ៦១៩ ៥០០ហ.ត។ វិធានការជួយសង្គ្រោះបន្ទាន់ និងវិធានការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិករ។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងខែកក្កដា ឆ្នាំ២០២២នេះ គឺបានរៀបចំកិច្ចប្រជុំការងារចាំបាច់ ការប្រជុំពិចម្ងាយ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២២ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងខែកក្កដាឆ្នាំ២០២២ នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ លទ្ធផលផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សា

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ២៤៣ ៤៩០ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៦ ០៣៤ហ.ត ស្មើនឹង០,២៧% និងដោយគ្រឿងយន្តចំនួន ២ ២៣៧ ៤៥៦ហ.ត ស្មើនឹង៩៩,៧៣% តិចជាងឆ្នាំមុន ៣០០ ៦៦១ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ៩ ៤៦៩ហ.ត តិចជាងឆ្នាំមុន ២ ៤៨៦ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ២ ១៦០ ១០១ហ.ត ស្មើនឹង៨២,៤៦% នៃផែនការចំនួន ២ ៦១៩ ៥០០ហ.ត តិចជាងឆ្នាំមុន ២៨៦ ១៨៥ហ.ត។

#### ១.២ ការប្រមូលផលស្រូវស្រាលរដូវវស្សា

ការប្រមូលផលស្រូវស្រាលសម្រេចបានចំនួន ១១៥ ៥៥៧ហ.ត ដោយទទួលបរិមាណផលសរុបចំនួន ៤៨៦ ៧៩៣តោន លើសឆ្នាំមុនចំនួន ៨៣ ៣៣៥តោន និងទទួលបានទិន្នផលគិតជាមធ្យម ៤,២១៣តោន/ហ.ត។

#### ១.៣ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវវស្សា

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៣៦ ៩០៥ហ.ត ស្មើនឹង៦៣,៧៤% នៃផែនការចំនួន ៥៧ ៩០០ហ.ត តិចជាងឆ្នាំមុន ១៦ ៧៨១ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៧២៩ ៨៧០ហ.ត ស្មើនឹង៩៣,៧៨% នៃផែនការចំនួន ៧៧៨ ៣០០ហ.ត តិចជាងឆ្នាំមុន ១ ៦២០ហ.ត។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

## ១.៤ ការនាំចេញផលិតផលកសិកម្ម

### ១.៤.១ ការនាំចេញអង្ករ

បរិមាណការនាំចេញអង្ករក្នុងខែកក្កដា ឆ្នាំ២០២២ មានចំនួន ២៣ ៧០២តោន ថយចុះចំនួន ៥ ៧១៣តោន (-១៩,៤២%) បើធៀបនឹងខែកក្កដា ឆ្នាំ២០២១ ដែលមានចំនួន ២៩ ៤១៥តោន។

បរិមាណការនាំចេញអង្ករមានចំនួន ៣៥០ ៩០២តោន កើនឡើងចំនួន ៤១ ០៣៧តោន (១៣,២៤%) បើធៀបនឹងបរិមាណនាំចេញក្នុងរយៈពេល៧ខែឆ្នាំ២០២១ ដែលមានចំនួន ៣០៩ ៨៦៥តោន។

អង្ករក្រអូបគ្រប់ប្រភេទមានចំនួន ២២៦ ៦៩៣តោន ស្មើនឹង៦៤,៦០% អង្ករសគ្រប់ប្រភេទមានចំនួន ១១៦ ៣៧៥តោន ស្មើនឹង៣៣,១៦% និងអង្ករចំហុយគ្រប់ប្រភេទមានចំនួន ៧ ៨៣៤តោន ស្មើនឹង២,២៤%។

បរិមាណអង្ករបាននាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន ២៣ប្រទេស មានបរិមាណសរុបចំនួន ១១៤ ៣៨០តោន (កើនឡើងចំនួន ៣៦ ៥៩៤តោន ស្មើនឹង ៤៧,០៤%) ទិសដៅប្រទេសចិនមានបរិមាណសរុបចំនួន ១៦៩ ៧៦៦តោន (កើនឡើងចំនួន ១៥ ៨៤៥តោន ស្មើនឹង ១០,២៩%) ទិសដៅអាស៊ានចំនួន ៤ប្រទេស មានបរិមាណសរុបចំនួន ២៩ ៩៥៧តោន (កើនឡើងចំនួន ៥០៤តោន ស្មើនឹង ១,៧១%) និងទិសដៅដទៃទៀតចំនួន ២៥ប្រទេស មានបរិមាណសរុប ៣៦ ៧៩៩តោន (ថយចុះចំនួន ១១ ៩០៦តោន ស្មើនឹង -២៤,៤៥%)។

ក្រុមហ៊ុនដែលបាននាំចេញអង្ករមានចំនួន ៥៣ក្រុមហ៊ុន ហើយបរិមាណអង្ករដែលបាននាំចេញដោយក្រុមហ៊ុនធំៗចំនួន១០ មានរហូតដល់ ២៤០ ៧៧៩តោន (៦៨,៦២%) និងក្រុមហ៊ុន ៤៣ដទៃទៀតបាននាំចេញត្រឹមតែ ១១០ ១២៣តោន (៣១,៣៨%)។

### ១.៤.២ ការនាំចេញស្រូវ

ក្នុងរយៈពេល៧ខែឆ្នាំ២០២២ ការនាំចេញស្រូវមានចំនួន ១ ៩៥០ ៩៨៦តោន ទៅកាន់ប្រទេសវៀតណាម (មានវិញ្ញាបនបត្រភូតគាមអនាម័យចំនួន ១ ៣២៩ ១០០តោន) មានការថយចុះចំនួន ៥៥ ២៥៥តោន (-២,៧៥%) បើធៀបនឹងរយៈពេល៧ខែ ឆ្នាំ២០២១ ដែលមានចំនួន ២ ០០៦ ២៤១តោន។

### ១.៤.៣ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករ

ក្នុងរយៈពេល៧ខែឆ្នាំ២០២២ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករមានចំនួន ៣ ៩០៨ ០០៨,៦០តោន កើនឡើងចំនួន ៤៧៥ ៤០៧,៥២តោន ស្មើនឹង ១៣,៨៥% បើធៀបនឹងរយៈពេល៧ខែ ឆ្នាំ២០២១ ដែលមានចំនួន ៣ ៤៣២ ៦០១,០៨តោន ដែលក្នុងនោះរួមមាន៖

- ចំណិតដំឡូងមីក្រៀមមានចំនួន ១ ៥៧៣ ៨៤០តោន (កើនឡើងចំនួន ២៥,៥១%) ក្នុងនោះនាំចេញទៅប្រទេសថៃចំនួន ១ ១៥៩ ០៥០តោន និងប្រទេសវៀតណាមចំនួន ៤១៤ ៧៩០តោន
- ដំឡូងមីស្រស់មានចំនួន ៨៤៦ ៣០០តោន (កើនឡើងចំនួន ១០០%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៥៤៤ ៨៥០តោន និងប្រទេសថៃចំនួន ៣០១ ៤៥០តោន
- ម្សៅដំឡូងមីមានចំនួន ៥០ ៧៦៣តោន (កើនឡើងចំនួន ១០០%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៤៨ ៨៩៥តោន សហរដ្ឋអាមេរិកចំនួន ៦៦តោន ប្រទេសអ៊ីតាលីចំនួន ៥៦៥តោន ប្រទេសវៀតណាម ចំនួន ២១០តោន ប្រទេសណេដឺឡែនចំនួន ១៥២តោន ប្រទេសកាណាដាចំនួន ១០២តោន ប្រទេសថៃចំនួន ៩៨,៦០តោន ប្រទេសម៉ាឡេស៊ីចំនួន ៣៨,៤០តោន ប្រទេសសិង្ហបុរីចំនួន ១៩តោន និងប្រទេសឥណ្ឌាចំនួន ១៧តោន
- កាកសំណល់ដំឡូងមីមានចំនួន ៧ ៦៧១,៣៩តោន (កើនឡើងចំនួន ៥៦,៣០%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៧ ១៧១,៣៩តោន និងប្រទេសវៀតណាមចំនួន ៥០០តោន
- គ្រាប់ស្វាយចន្ទីឆៅមានចំនួន ៤៤៥ ០១៥,១៥តោន (ថយចុះចំនួន -៤៨,៥៧%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៤៤២ ៨០១,២២តោន ប្រទេសថៃចំនួន ២ ០៥០តោន ប្រទេសឥណ្ឌាចំនួន ១៥០,១៦តោន ប្រទេសចិនចំនួន ១៣,៥៨តោន ប្រទេសជប៉ុនចំនួន ០,១៤តោន និងប្រទេសហ្វីលីពីនចំនួន ០,០៥តោន
- គ្រាប់ស្វាយចន្ទីកែច្នៃមានចំនួន ៤៣៣,៨២តោន (ថយចុះចំនួន -៥៦,៩៥%) ក្នុងនោះនាំចេញទៅប្រទេសថៃចំនួន ២១០,០១តោន ប្រទេសចិនចំនួន ១៧៧,៦៤តោន កោះតៃវ៉ាន់ចំនួន ២៤តោន និងប្រទេសជប៉ុនចំនួន ២២,១៧តោន
- គ្រាប់ពោតមានចំនួន ១៣៣ ៨៤៨,៩០តោន (ថយចុះចំនួន -៨,៥១%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៨៥ ៤៩០តោន ប្រទេសថៃចំនួន ៤៧ ៥០០តោន កោះតៃវ៉ាន់ចំនួន ៨៤៦,៦០តោន និងប្រទេសកូរ៉េចំនួន ១២,៣០តោន

- គ្រាប់សណ្តែកបាយមានចំនួន ៣២ ៧៧៥,០១តោន (កើនឡើងចំនួន ៥៤,៣៨%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៣២ ៧៧៥តោន និងប្រទេសជប៉ុនចំនួន ០,០១តោន

- គ្រាប់សណ្តែកសៀងមានចំនួន ៧០ ៤៨៥តោន (កើនឡើងចំនួន ១០០%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៦៥ ៥៣៥តោន និងប្រទេសថៃចំនួន ៤ ៩៥០តោន

- ផ្លែចេកស្រស់មានចំនួន ២៥០ ៥៥០,៤៦តោន (ថយចុះចំនួន -៧,២៨%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ២២៦ ១៥៣,៧៩តោន ប្រទេសវៀតណាមចំនួន ២៤ ៣៩៦,៦២តោន និងប្រទេសជប៉ុនចំនួន ០,០៥តោន

- ផ្លែស្វាយស្រស់មានចំនួន ១១៧ ៩៥១,៥៥តោន (ថយចុះចំនួន -២៦,៨៤%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៦២ ៦៤០,២៣តោន ប្រទេសថៃចំនួន ២៧ ៦៨១,១២តោន ប្រទេសចិនចំនួន ២៧ ៤៦៧,៨៨តោន ប្រទេសកូរ៉េចំនួន ១៦០,០៨តោន និងទីក្រុងហុងកុងចំនួន ២,២៤តោន

- ដំណាប់ស្វាយមានចំនួន ១៣ ២២៤,៤១តោន (ថយចុះចំនួន -២,២២%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ១១ ៥៧៣,៣៧តោន ប្រទេសថៃចំនួន ៨៣៦,០២តោន ប្រទេសហ្វីលីពីនចំនួន ៤៩៩,៩៦តោន ប្រទេសវៀតណាមចំនួន ២០០តោន ប្រទេសជប៉ុនចំនួន ៤៨,៣៨តោន ប្រទេសរុស្សីចំនួន ៤៥,៥៨តោន ចក្រភពអង់គ្លេសចំនួន ៩,៧៨តោន ប្រទេសអ៊ីតាលីចំនួន ៦,៣០តោន ប្រទេសកូរ៉េចំនួន ៤,៩៩តោន និងសហរដ្ឋអាមេរិក ចំនួន ០,០៣តោន

- ដូងប្រេងមានចំនួន ២៨ ៦២៨,៧០តោន (ថយចុះចំនួន -៣,៣៤%) ក្នុងនោះនាំចេញទៅប្រទេសឥណ្ឌាចំនួន ២៣ ៤៨៦,៧០តោន ប្រទេសម៉ាឡេស៊ីចំនួន ៤ ៩៥០តោន និងប្រទេសថៃចំនួន ១៩២តោន

- ម្រេចមានចំនួន ៦ ៩៩០,០៧តោន (ថយចុះចំនួន -៦៩,០៤%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៦ ២៩៨,៨៩តោន ប្រទេសអាល្លឺម៉ង់ចំនួន ៦០៨,៤៤តោន កោះតៃវ៉ាន់ចំនួន ២១តោន ប្រទេសបារាំងចំនួន ១៥,០៨តោន ប្រទេសម៉ាឡេស៊ីចំនួន ១៣,៦៤តោន ប្រទេសប៊ែលហ្ស៊ិកចំនួន ១៣,២៤តោន សាធារណរដ្ឋឆេក ចំនួន ៨,១៨តោន ប្រទេសជប៉ុនចំនួន ២,៩៤តោន ប្រទេសស៊ុយអ៊ែតចំនួន ២,៧៨តោន ប្រទេសកាណាដាចំនួន ១,២៨តោន សហរដ្ឋអាមេរិក ចំនួន ០,៩២តោន ប្រទេសឥណ្ឌាចំនួន ០,៩២តោន ចក្រភពអង់គ្លេសចំនួន ០,៩០តោន ប្រទេសកូរ៉េចំនួន ០,៦២តោន ប្រទេសលីទុយអានីចំនួន ០,៤៥តោន ប្រទេសស្វីសចំនួន ០,៤០តោន ប្រទេស កាហ្សាក់ស្ថានចំនួន ០,២៩តោន និងប្រទេសអូស្ត្រាលីចំនួន ០,១០តោន

- ថ្នាំជក់មានចំនួន ៤ ៧៨៩,៦៨តោន (កើនឡើងចំនួន ១០០%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៤ ៦៨៧,៧០តោន កោះតៃវ៉ាន់ចំនួន ៤៧,២៥តោន ប្រទេសហុងគ្រីចំនួន ៣៩,៦០តោន ប្រទេសហ្វីលីពីនចំនួន ១៥,១១តោន និងប្រទេសអាហ្វ្រិកខាងត្បូងចំនួន ០,០២តោន

- បន្លែចម្រុះមានចំនួន ៥៦,៧៨តោន ក្នុងនោះនាំចេញទៅប្រទេសបារាំងចំនួន ៥៦,៧៤តោន និងប្រទេសនូវែលសេឡង់ចំនួន ០,០៤តោន

- ផលិតផលចំនួន ៧៣មុខ ផ្សេងទៀតមានចំនួន ៣២៤ ៦៨៤,៦៩តោន។

### ១.៤.៤ ការប៉ាន់ស្មានតម្លៃនៃការនាំចេញកសិផល

ការប៉ាន់ស្មានតម្លៃគិតជាទឹកប្រាក់ក្នុងរយៈពេល៧ខែឆ្នាំ២០២២ ដែលទទួលបានពីការនាំចេញកសិផល (ឯកតាតម្លៃផ្អែកតាមវិក្កយបត្ររបស់អ្នកនាំចេញ) មានចំនួន ២ ៤៤១ ៣៩៩ ១៦១,៤៧ដុល្លារអាមេរិក ដែលក្នុងនោះ៖

- ការនាំចេញអង្ករមានចំនួន ៣០០ ០២១ ២១០ដុល្លារអាមេរិក
- ការនាំចេញស្រូវមានចំនួន ៣៨៦ ២៩៥ ២២៨ដុល្លារអាមេរិក
- ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករមានចំនួន ១ ៧៥៥ ០៨២ ៧២៣,៤៧ដុល្លារអាមេរិក។

## ២ ផ្នែកផលិតកម្មកៅស៊ូ

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ០៤៤ហ.ត ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិ-ឧស្សាហកម្មចំនួន ៤៧ ៩៤៤ហ.ត ផ្ទៃដីចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ចចំនួន ១៩២ ៤០២ហ.ត និងផ្ទៃដីចម្ការកៅស៊ូគ្រួសារចំនួន ១៦៣ ៦៩៨ហ.ត។ ផ្ទៃដីចៀរជ័រចំនួន ៣១០ ១៩៣ហ.ត ស្មើនឹង៧៧% និងផ្ទៃដីថែទាំចំនួន ៩៣ ៨៥១ហ.ត ស្មើនឹង២៣%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូខែមិថុនាសម្រេចបានចំនួន ៣០ ២២០តោន កើនឡើងចំនួន ៣ ៧១៥តោន ស្មើនឹង១៤% ធៀបខែមុន និងថយចុះ៥០៥តោន ស្មើនឹង២% ធៀបខែមិថុនា ឆ្នាំ២០២១

- ផលិតផលឈើកៅស៊ូខែមិថុនាសម្រេចបានចំនួន ២ ៨៣៨ម³ ថយចុះចំនួន ៣ ១៥៥ម³ ស្មើនឹង៥៣% ធៀបខែមុន

**២.៣ ការនាំចេញកៅស៊ូ**

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូខែមិថុនាសម្រេចបានចំនួន ៣០ ០៨៩តោន កើនឡើងចំនួន ៤ ៣៩៩តោន ស្មើនឹង១៧% ធៀបខែមុន និងកើនឡើងចំនួន ១ ១៥៨តោន ស្មើនឹង៤% ធៀបខែមិថុនា ឆ្នាំ២០២១

- បរិមាណបញ្ចេញលក់ឈើកៅស៊ូខែមិថុនាសម្រេចបានចំនួន ២ ៥៤៦ម³ ថយចុះចំនួន ២ ៨៩៧ម³ ស្មើនឹង ៥៣% ធៀបខែមុន

**២.៤ តម្លៃកៅស៊ូ**

- តម្លៃលក់ជ័រកៅស៊ូមធ្យមខែមិថុនា គឺ១ ៥៧២ដុល្លារ/តោន ថយចុះចំនួន ២៩ដុល្លារ/តោន ស្មើនឹង២% ធៀបខែមុន និងថយចុះចំនួន ១៦២ដុល្លារ/តោន ស្មើនឹង៩% ធៀបខែមិថុនា ឆ្នាំ២០២១

- តម្លៃលក់ឈើកៅស៊ូមធ្យមខែមិថុនា គឺ១៤១ដុល្លារ/ម³

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារខែមិថុនា គឺទឹកជ័រ (DRC 100%) មានការប្រែប្រួលពី ៥ ៨០០៛/គ.ក្រ ដល់ ៦ ១៧៥៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ២ ៥០០៛/គ.ក្រ ដល់ ៣ ២០០៛/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- ទាញយករូបភាពផ្កាយរណប (SENTINEL_2) ឆ្នាំ២០២២ ចំនួន ៥ផ្ទាំង និងបានចាត់ថ្នាក់បឋមសម្រាប់ចុះពិនិត្យជាក់ស្តែងនៅទីវាល

- ចុះធ្វើការប្រមូលព័ត៌មាននៅទីវាលជាក់ស្តែងតាមចំណុចនិយាមកាមួយចំនួនដែលបានធ្វើការចាត់ថ្នាក់បឋមតាមរូបភាពផ្កាយរណប SENTINEL-2 ក្នុងកម្មវិធី eCognition ហើយមានភាពមិនច្បាស់លាស់ ដើម្បីធ្វើការផ្ទៀងផ្ទាត់ និងវាយតម្លៃកម្រិតជឿជាក់នៅខេត្តកំពង់ធំចំនួន ៥០២ចំណុច

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនអ្នកស្នើសុំចំនួន ២នាក់ មានជ័រទឹកចំនួន ១២៣តោន។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- ចុះពិនិត្យម៉ាស៊ីនថតរូបស្វ័យប្រវត្តិចំនួន ៥គ្រឿង ដើម្បីសិក្សា តាមដាន អង្កេតសត្វព្រៃ និងបញ្ហា ប្រឈមផ្សេងៗដែលកើតមាននៅក្នុងតំបន់សហគមន៍ព្រៃឈើប្រាសាទទឹកខ្មៅ ខេត្តក្រចេះ

- ចុះពង្រឹងការថែរក្សាសត្វព្រៃចំនួន ១លើកនៅខេត្តក្រចេះ ដោយដោះអន្ទាក់ចំនួន៥១ខ្សែ និងយកទៅរក្សាទុកនៅសង្កាត់រដ្ឋបាលព្រៃឈើវត្តឡុងៈ

- ចុះសិក្សាកំណត់តំបន់សក្តានុពលទេសចរណ៍ធម្មជាតិចំនួន១លើកនៅខេត្តមណ្ឌលគិរី

- ចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃជូនក្រុមហ៊ុនចំនួន៦ច្បាប់មានស្វាក្តាមចំនួន ២ ៦៧៩ក្បាល សម្រាប់ដឹកជញ្ជូនទៅកាន់មាត់ច្រកអន្តរជាតិនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និង២៩៧ក្បាល ដឹកជញ្ជូនក្នុងស្រុក។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន៧ដែលមានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញចំនួន ៨ទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំងមានស្វាក្តាមសរុបចំនួន ១៣១ ៦៣១ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ៨ ៣៦៦ក្បាល

- កំពុងថែរក្សាសត្វព្រៃចំនួន ១ ៧៩៧ក្បាល (បក្សីចំនួន ៥៩ប្រភេទ ថនិកសត្វចំនួន ៤៤ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ)

- សង្គ្រោះសត្វព្រៃថ្មីចំនួន ៦៦ក្បាល និងព្យាបាលចំនួន ៤៧ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI ក្រុមល្បាតចំនួន ២៦នាក់ បានចុះល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥គឺ អារ៉ែង ឆាយរាប តំបន់ស្គារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- ជួសជុលផ្លូវក្រាលក្រួសក្រហមប្រវែង ៣ ៩០០ម៉ែត្រ និងកាប់ឆ្ការអនាម័យព្រៃទំហំ ១ហ.ត។

### ៣.៤ ការងារដាំដើមឈើ

- បាននិងកំពុងថែទាំចម្ការឈើសរុបទំហំ ៧៤៧ហ.ត ក្នុងនោះ មានចម្ការពូជឈើទំហំ ៩៤ហ.ត ឡូតិ៍បង្ហាញកសិ-រុក្ខកម្មទំហំ ៣៩ហ.ត ចម្ការឈើដាំទំហំ ៥៨៤ហ.ត និងចម្ការរុក្ខទិវា ៩ កក្កដា សរុបទំហំ ៣០ហ.ត ស្ថិតក្នុងខេត្តកំពតកណ្តាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ

- បណ្តុះកូនឈើគ្រប់ប្រភេទសរុបចំនួន ៥១ ៩៨១ដើម និងចែកចាយកូនឈើសម្រាប់ដាំអាស្រ័យផលបានចំនួន ៥២ ៥៣៥ដើម

- បង្កើតចម្ការពូជឈើក្នុងស្រុកលើផ្ទៃដី ១០ហ.ត នៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអូរបឹងរូង១ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ បានដាំដុះប្រភេទឈើធ្នង់ទំហំ ៥ហ.ត និងឈើកកោះ ៥ហ.ត។

### ៣.៥ ការងារនីតិកម្ម និងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើសរុបចំនួន ៦៦ករណី ក្នុងនោះ សំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន ១៤ករណី និងសំណុំរឿងបទល្មើសព្រៃឈើត្រូវបញ្ជូនទៅតុលាការចំនួន ៥២ករណី

- វត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់យាត់ និងដកហូតរួមមាន ឈើមូល-ជ្រុងចំនួន ១៩ម³ ឈើអារចំនួន ៨៩ម³ សត្វព្រៃចម្រុះប្រភេទចំនួន ១០ក្បាល និង២៥គ.ក្រ ផ្ទៃដីព្រៃឈើដែលបានកាប់រានទំហំ ៤៥០ហ.ត និងអនុផលព្រៃឈើមួយចំនួនទៀត

- វត្ថុតាងជាសត្វព្រៃ និងសំណាកសត្វព្រៃប្រមូលតាមរយៈការប្រគល់-ទទួលចំនួន ៣៥ករណី ធ្វើកិច្ចសន្យាចំនួន ២ករណី ធ្វើការដកហូតចំនួន ១០ករណី មានសត្វព្រៃរស់ចម្រុះប្រភេទចំនួន ១១ក្បាល សត្វព្រៃងាប់ចម្រុះប្រភេទចំនួន ២៣៦ក្បាល

- ធ្វើបច្ចុប្បន្នភាពសំណុំរឿងបទល្មើសព្រៃឈើ និងសត្វព្រៃតាមការបង់ប្រាក់ពិន័យដោយតុលាការចំនួន ៧ករណី។

### ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- ចុះពិនិត្យសំណើសុំពន្យារសុពលភាពរោងម៉ាស៊ីនអារកែច្នៃឈើចំនួន ២កន្លែង ស្ថិតនៅខេត្តក្រចេះ និងខេត្តមណ្ឌលគិរី និងសំណើសុំពន្យារសុពលភាពរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន ១កន្លែង ស្ថិតនៅខេត្តកំពង់ចាម

- ក្រុមហ៊ុនចំនួន២នាំចេញផលិតផលរានទេវតា និងឈើបន្ទះក្តារកែច្នៃទៅក្រៅប្រទេសចំនួន ៣៦៦ម³

- ក្រុមហ៊ុនចំនួន៣នាំចូលឈើកែច្នៃមានបរិមាណចំនួន ២៥២ម³

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន២មានបរិមាណឈើកែច្នៃចំនួន ៧៦ម³ និងគ្រឿងសង្ហារិមឫស្សីកែច្នៃចំនួន ១៩តោន

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន១ មានឈើកែច្នៃចំនួន ៥០១ម³។

### ៣.៧ ការងារចំណូលព្រៃឈើ

- ចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើចំនួនសរុប ៣៩៣ ៩៩៨ ៤៧១រៀល និង៥៥២ ៧៤០,៨៣ដុល្លារ។

## ៤ ផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្មូនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

### ៤.២ ការងារសុខភាពសត្វ

- លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖ ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសចលនាសត្វ និងផលិតផលសត្វសរុបចំនួន ២០ករណី ក្នុងនោះ ត្រួតពិនិត្យមានលិខិតអនុញ្ញាតត្រឹមត្រូវ១៩ករណី និងមិនមានលិខិតអនុញ្ញាតត្រឹមត្រូវ១ករណី (បទល្មើស) ។ រាជធានី-ខេត្តចំនួន ២៤បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ១៥ ២១៧លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។

- **ការងារផ្សព្វផ្សាយបច្ចេកទេស**

- ចុះបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ និងជំងឺឆ្លងសត្វដល់កសិករ និងអ្នកពាក់ព័ន្ធក្នុងខេត្តចំនួន៣។

- **ការងារនីតិកម្ម និងវិវាទ**

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានលើសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេសនិងនីតិកម្មលើសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសបសុព្យាបាលសម្រាប់ទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងអាជីវកម្មសត្វ។

### ៤.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១១៨ក្បាល។
- **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបបានចំនួន ២ ២៦៥វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។ វត្ថុវិភាគចំនួន១៦ មានប្រភពមកពីប្រទេសវៀតណាមតាមរយៈការនាំចូលជ្រូករស់ខុសច្បាប់មានវត្តមានមេរោគជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) វត្ថុវិភាគចំនួន៦ មានប្រភពមកពីខេត្តសៀមរាប កំពង់ចាម និងខេត្តត្បូងឃ្មុំ មានវត្តមានជំងឺដុំពកស្បែកគោ ក្របី (LSD) និងវត្ថុវិភាគចំនួន៤ មានប្រភពពីខេត្តត្បូងឃ្មុំមានវត្តមានជំងឺអុតក្តាមគោ ក្របី (FMD)។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ជាយត្រីសម្រេចបានត្រឹមខែមីនាចំនួន ៦៥០តោន ស្មើនឹង៦,៥០% នៃផែនការចំនួន ១០ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០២១ ថយចុះចំនួន ៦៦០តោន

- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ១៦ ៩០០តោន សរុបរយៈពេល៧ខែចំនួន ១១១ ៧០០តោន ស្មើនឹង ៣៧,២៣%នៃផែនការចំនួន ៣០០ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០២១ ថយចុះចំនួន ៤១ ៧០០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ៤ ១០០តោន សរុបរយៈពេល៧ខែចំនួន ២៥ ២០០តោន ស្មើនឹង១៨% នៃផែនការចំនួន ១៤០ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០២១ ថយចុះចំនួន ១០០តោន។

#### ៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ១០ ៨០០តោន សរុបរយៈពេល៧ខែចំនួន ៦៨ ៦០០តោន ស្មើនឹង៥២,៧៧% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០២១ កើនឡើងចំនួន ៧០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ៣៣ ០០០តោន សរុបរយៈពេល៧ខែចំនួន ២០១ ៣០០តោន ស្មើនឹង ៥៥,៩២% នៃផែនការចំនួន ៣៦០ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០២១ កើនឡើងចំនួន ៥៣ ៨៨៨តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ១៥ ០០០ក្បាល សរុបរយៈពេល៧ខែចំនួន ៧០ ៣០០ក្បាល ស្មើនឹង២៣,៤៣% នៃផែនការចំនួន ៣០០ ០០០ក្បាល ប្រៀបធៀបខែកក្កដា ឆ្នាំ២០២១ ថយចុះចំនួន ៧២ ១០០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ១៥ ៩០០ ០០០កូន សរុបរយៈពេល៧ខែចំនួន ៨៩ ៧០០ ០០០កូន ស្មើនឹង ២៩,៩០%នៃផែនការចំនួន ៣០០ ០០០ ០០០កូន ប្រៀបធៀបខែកក្កដា ឆ្នាំ២០២១ ថយចុះចំនួនប្រមាណ ៣២ ៨០០ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ៣ ០០០តោន សរុបរយៈពេល៧ខែចំនួន ២៤ ៥០០តោន ស្មើនឹង៣០,៦៣% នៃផែនការចំនួន ៨០ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០២១ ថយចុះចំនួន ៧ ៤១០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ៩៩០តោន សរុបរយៈពេល៧ខែចំនួន ៦ ៨៦០តោន ស្មើនឹង៥៧,១៧% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០២១ ថយចុះចំនួន ១០០តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៤ ០០០ ០០០លីត្រ សរុបរយៈពេល៧ខែចំនួន ៣៥ ៧៥០ ០០០លីត្រ ស្មើនឹង ៧១,៥០% នៃផែនការចំនួន ៥០ ០០០ ០០០លីត្រ ប្រៀបធៀបខែកក្កដា ឆ្នាំ២០២១ ថយចុះចំនួន ១ ០០៨ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ៣៥០ករណី ប្រៀបធៀបខែកក្កដា ឆ្នាំ២០២១ ថយចុះចំនួន ១៩៣ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ៣៤៩ករណី និងសមុទ្រចំនួន ១ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញចំនួន ៤៨៤តោន សរុបរយៈពេល៧ខែចំនួន ១ ៩៣៣តោន ស្មើនឹង២៤,១៦% នៃផែនការចំនួន ៨ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០២១ ថយចុះចំនួន ៣២៦តោន

- ផលនេសាទកែច្នៃនាំចេញ សរុបរយៈពេល៧ខែចំនួន ៤១តោន ស្មើនឹង២,០៥% នៃផែនការចំនួន ២ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០២១ ថយចុះចំនួន ១០៩តោន។

### ៥.៦ ការប្រមូលចំណូល

- ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលបានចំនួន ១៨ ៩២០ ០០០រៀល សរុបរយៈពេល៧ខែចំនួន ៤៣៤ ៦២៣ ៥០៣រៀល ស្មើនឹង១២១% នៃផែនការចំនួន ៣៥៩ ២០០ ០០០រៀល ប្រៀបធៀបខែកក្កដា ឆ្នាំ២០២១ កើនឡើងចំនួន ៩ ៦៩៧ ៣៧៥រៀល។

## ៦ ផ្នែកអគ្គាធិការដ្ឋាន

- ចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច ការផ្តល់សេវាសាធារណៈ ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- ត្រួតពិនិត្យនូវបណ្តាវិធានការរបស់គណៈប្រតិភូអធិការកិច្ចក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្នុងការិយបរិច្ឆេទ២០១៨ អគ្គាធិការដ្ឋានរដ្ឋបាលជលផលសមុទ្រនៅខេត្តព្រះសីហនុ

- ចុះពិនិត្យតាមដាន និងវាយតម្លៃលើការងារបង្ក្រាបបទល្មើសជលផលនៅខេត្តបាត់ដំបង

- ស្រាវជ្រាវព័ត៌មានតាមបណ្តាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៧៨ករណី លើវិស័យព្រៃឈើ២៦ករណី ជលផល២៤ករណី សុខភាពសត្វនិងផលិតកម្មសត្វ៨ករណី ក្សេត្រសាស្ត្រ១ករណី និងវិស័យផ្សេងៗ១៩ករណី។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៨៤៩ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ៣៣៧ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៣៦៥ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១៤៧ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ១ ១៧៨ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ១៨ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ៤៧ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែកក្កដា

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- រៀបចំកិច្ចប្រជុំផ្ទៃក្នុង (អន្តរនាយកដ្ឋាន) ចំនួន ៧លើក មានសមាជិកចូលរួមចំនួន ២៣៦នាក់ និងកិច្ចប្រជុំអន្តរក្រសួងចំនួន ២លើក មានសមាជិកចូលរួមចំនួន ៨៥នាក់

- ទទួលភ្ញៀវអន្តរជាតិចំនួន ៣លើក មានសមាជិកចូលរួមចំនួន ៤៥នាក់

- សិក្ខាសាលាចំនួន ៥លើក មានសមាជិកចូលរួមចំនួន ៨៩២នាក់

- សរុបការរៀបចំកិច្ចប្រជុំ និងការទទួលភ្ញៀវមានចំនួន ១៧លើក មានសមាជិកចូលរួមចំនួន ១ ២៥៨នាក់

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញ ផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៥ ៩៥២នាក់ (ស្រី១ ៤៧៩នាក់ ស្មើនឹង២៤,៨៨%) រួមមានៈ
  + អង្គភាពថ្នាក់កណ្តាលចំនួន ៣ ០១៨នាក់ (ស្រី៨៧២នាក់ ស្មើនឹង២៨,៨៩%)
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩៣៤នាក់ (ស្រី៦០៧នាក់ ស្មើនឹង២០,៧០%)

- រៀបចំប្រកាសស្ដីពីការទទួលស្គាល់មន្ត្រីរាជការផ្ទេរមកពីក្រៅក្រសួងចំនួន ៤នាក់
- រៀបចំលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកសរុបចំនួន ១៦នាក់ (ស្រី១២នាក់)
- រៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន ៤នាក់
- ការងារបណ្ដុះបណ្ដាលក្នុង និងក្រៅប្រទេសសរុបចំនួន ៣០០នាក់ (ស្រី៦១នាក់) ក្នុងនោះ៖
  + ការបណ្ដុះបណ្ដាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ២៨៩នាក់ (ស្រី៥៨នាក់)
  + ការបណ្ដុះបណ្ដាលក្រៅប្រទេសចំនួន ១១នាក់ (ស្រី០៣នាក់)។

## ៩ ផ្នែកផែនការ និងស្ថិតិ

- រៀបចំលិខិតណែនាំស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ ទៅអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត
- ផ្ញើលិខិតឆ្លើយតបទៅសំណើសុំពិនិត្យ និងផ្ដល់យោបល់លើសេចក្ដីព្រាងស្ដីពីការវាយតម្លៃគោលនយោបាយ និងការគ្រប់គ្រងប្រទេសឆ្នាំ២០២២
- រៀបចំលិខិតលើគម្រោងស្នើសុំទៅទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិថៃ (TICA) ដើម្បីរៀបចំផែនការសកម្មភាពឆ្នាំ២០២៣-២០២៧
- ទទួលរបាយការណ៍ពីបណ្ដារាជធានី-ខេត្តពាក់ព័ន្ធការងារស្ថិតិកសិកម្ម
- ចូលរួមប្រជុំពិនិត្យ ពិភាក្សាលើតារាងសំណួរកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ ផ្អែកលើតារាងសំណួរជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣ និងការងារពាក់ព័ន្ធផ្សេងៗ
- ចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្ដាហ៍បីដង គឺថ្ងៃច័ន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយម្ដងក្នុងសប្ដាហ៍រៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្ដាទីផ្សារសំខាន់ៗ ទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្ដារាជធានី-ខេត្តទាំង២៥
- ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីការវិភាគទិន្នន័យអង្កេតកសិកម្មសម្រាប់វាស់វែងសូចនាករគោលដៅអភិវឌ្ឍដោយចីរភាព (SDG ២.៤.១) នៅខេត្តសៀមរាប
- ចូលរួមត្រួតពិនិត្យ និងវាយតម្លៃផ្នែកបរិស្ថាន និងសង្គមគម្រោង CERC-MAFF និងប្រមូលព័ត៌មានរៀបចំក្រមប្រតិបត្តិបរិស្ថាន (ECOP) គម្រោង CERC ក្របខ័ណ្ឌ MoWRAM នៅខេត្តកំពង់ឆ្នាំង បាត់ដំបង សៀមរាប និងខេត្តព្រះវិហារ។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- អង្គភាពប្រមូលចំណូលទាំង៦បានចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS) សរុបទឹកប្រាក់ចំនួន៥ ៣៩៦លានរៀល
- បញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបមានចំនួន ៧ ០៩២លានរៀល
- ទទួលថ្លៃសម្បទានដីសេដ្ឋកិច្ចចំនួន ១៩ក្រុមហ៊ុន
- រៀបចំសំណើសុំថវិកាចំនួន ៣១ ៨៨៥,២៦ដុល្លារអាមេរិក ដើម្បីបំពេញឡើងវិញចូលគណនីបដិភាគរបស់រាជរដ្ឋាភិបាលសម្រាប់កម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្នផ្នែកវារីវប្បកម្ម (CaPFish Aquaculture) ក្រោមហិរញ្ញប្បទានឥតសំណងរបស់ទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ (AFD)
- ទទួលឥណទានធានាចំណាយចំនួន៤គម្រោង និងបានរៀបចំឯកសារដេញថ្លៃ ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងៗដើម្បីដំណើរការអនុវត្តកិច្ចលទ្ធកម្ម
- ចុះពិនិត្យ និងផ្ទៀងផ្ទាត់តារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២១ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ និងខេត្តតាកែវ។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- រៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះក្នុងឆ្នាំ២០២១ ធ្វើសំណើសុំជម្រះសម្ភារខូចខាតប្រើប្រាស់លែងកើត និងធ្វើការគ្រប់គ្រង បែងចែកសម្ភារការិយាល័យ សង្ហារិម សម្ភារបរិក្ខារបច្ចេកទេស ថែទាំ និងជួសជុល
- រៀបចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់ M1 ប្រចាំត្រីមាស

- ចុះធ្វើសវនកម្មចំនួន ១៦សវនដ្ឋាន ស្មើនឹង៤១,១០% នៃផែនការ៣៩សវនដ្ឋាន ដោយរកឃើញលទ្ធផលសវនកម្ម និងផ្តល់អនុសាសន៍សម្រាប់សវនដ្ឋានកែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងចំនួន៥០អនុសាសន៍ និងការអនុវត្តអនុសាសន៍គ្រាមុនរបស់សវនដ្ឋានសម្រេចបានចំនួន ៥៩,៨៤% នៃផែនការចំនួន៥៦%។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- សម្របសម្រួលធ្វើលិខិតករណីចិនស្នើកម្ពុជាធ្វើជា Co-Sponsor លើឯកសារទស្សនទាន ដើម្បីរៀបចំសិក្ខាសាលាវេទិកាតំបន់អាស៊ានស្តីពីវិធានការកសាងទំនុកចិត្ត និងបង្ការផ្នែកការទូតសម្រាប់ដោះស្រាយបញ្ហាប្រឈមសន្តិសុខស្បៀងនៅតំបន់អាស៊ីប៉ាស៊ីហ្វិក

- សម្របសម្រួលធ្វើលិខិតករណីសំណើសុំអនុញ្ញាតរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំសម្រាប់រៀបចំផែនការគ្រប់គ្រង អភិវឌ្ឍន៍ និងផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីការចុះបញ្ជីព្រៃឯកជននៅកម្ពុជា

- សម្របសម្រួលធ្វើលិខិតករណីការជួញដូរសត្វស្វាខុសច្បាប់ពីកម្ពុជាទៅសហរដ្ឋអាមេរិក

- សម្របសម្រួលធ្វើលិខិតជារបាយការណ៍វឌ្ឍនភាពកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្មរវាងភាគីចិន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីអនុវត្តបញ្ជីការងារបន្ទាន់

- សម្របសម្រួលធ្វើលិខិតករណីស្នើសុំចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងអគ្គកៅស៊ូ និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (The NGO Forum on Cambodia)។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៣៥ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២១ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៧ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៧ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ២ក្រុមហ៊ុន។

### ១៣.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ១៤ក្រុមហ៊ុន សរុបចំនួន ១៦១សំណាក។

### ១៣.៣ ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត

- សហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈនៅខេត្តសៀមរាប។

### ១៣.៤ ការងារអនុវត្តច្បាប់

- ចុះត្រួតពិនិត្យក្រុមហ៊ុនប្រកាសប្រតិវេទន៍នាំចូលថ្នាំកសិកម្ម ជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយដល់ក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៨ក្រុមហ៊ុន។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- ថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងសរុបចំនួន ១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

- ចុះតាមដាន និងពង្រឹងការប្រើប្រាស់គេហទំព័ររបស់មន្ទីរ និងប្រមូលធាតុចូលសម្រាប់បង្កើតកម្មវិធីទូរស័ព្ទនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ធំ និងខេត្តសៀមរាប

- សម្អាត Cache នៅលើ Cloud server នៃគេហទំព័រទាំង៤១ និងតាមដានទិន្នន័យដែលផ្ទុកនៅលើ Cloud server នៃគេហទំព័រទាំង៤១

- ទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្តីដែលទទួលបានពីនាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្នែកផ្សេងៗសរុបចំនួន ៨៣ក្បាល/ច្បាប់។

## ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ចុះថត និងផលិត Video បទយកការណ៍ចំនួន ៧ប្រធានបទ

- ធ្វើការចាក់ផ្សាយឡើងវិញវេទិកាស្វែងយល់អំពីកសិកម្មចំនួន ៨ប្រធានបទ
- ធ្វើការចាក់ផ្សាយឡើងវិញនាទីចុះស្រែជាមួយកសិករចំនួន ៨ប្រធានបទ
- ធ្វើការចាក់ផ្សាយអត្ថបទបច្ចេកទេសកសិកម្មជាសំឡេងនៅស្ថានីយវិទ្យុជាតិ FM105.70.75MHZ ចំនួន ៣៦ប្រធានបទ
- ផ្សព្វផ្សាយពី Video បច្ចេកទេសកសិកម្មចំនួន ៦៦Video ឯកសារជាអត្ថបទបច្ចេកទេសកសិកម្មចំនួន ៧២ឯកសារ
- ជួយដោះស្រាយបញ្ហា និងផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជនចំនួន ២២សំណួរ-ចម្លើយលើប្រធានបទបច្ចេកទេសចិញ្ចឹមមាន់ ទា គោ កង្កែប ដំឡូងមី ពោត ស្រូវ សណ្តែក ស្ពៃ ដំណាំម្ទេស និងដំណាំផ្សិត មកពីខេត្តពោធិ៍សាត់ ត្បូងឃ្មុំ កំពង់ស្ពឺ កំពង់ឆ្នាំង តាកែវ កណ្តាល កំពង់ចាម ស្វាយរៀង បន្ទាយមានជ័យ បាត់ដំបង ព្រៃវែង និងរាជធានីភ្នំពេញ។

## ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- អនុវត្តកិច្ចសន្យាផលិតកម្មកសិកម្មចំនួន ១៨១កិច្ចសន្យា គិតត្រឹមថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២ រួមមានខេត្តពោធិ៍សាត់៣៣កិច្ចសន្យា ស្ទឹងត្រែង៧កិច្ចសន្យា តាកែវ១កិច្ចសន្យា មណ្ឌលគិរី១កិច្ចសន្យា កំពង់ស្ពឺ២៨កិច្ចសន្យា កែប៤កិច្ចសន្យា កណ្តាល៨កិច្ចសន្យា ក្រចេះ១៤កិច្ចសន្យា ព្រះវិហារ១កិច្ចសន្យា ត្បូងឃ្មុំ២០កិច្ចសន្យា សៀមរាប ១១កិច្ចសន្យា កំពង់ចាម៤កិច្ចសន្យា ស្វាយរៀង៣កិច្ចសន្យា បន្ទាយមានជ័យ១៥កិច្ចសន្យា កំពង់ធំ៧កិច្ចសន្យា ប៉ៃលិន ១២កិច្ចសន្យា និងខេត្តកំពង់ឆ្នាំង១២កិច្ចសន្យា
- ចុះជ្រើសរើសសិប្បកម្មកែច្នៃផលិតផលកសិកម្មនៅខេត្តព្រះវិហារ
- បាននិងកំពុងសហប្រតិបត្តិការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) សិក្សាគម្រោងធ្វើឱ្យប្រសើរឡើងនូវច្រវាក់តម្លៃផលិតផលកសិកម្មក្នុងប្រទេសកម្ពុជា (Improvement of Agricultural Value Chain in Cambodia) ក្នុងគោលបំណងលើកកម្ពស់ចំណូលប្រជាជនជនបទបង្កើនគុណភាព និងបរិមាណផលិតផលកសិកម្មផ្សារភ្ជាប់ទីផ្សារ និងតម្លៃបន្ថែម
- បាននិងកំពុងរៀបចំសេចក្តីព្រាងប្រកាសស្តីពីស្លាកសញ្ញាបញ្ជាក់គុណភាព សុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហារកម្ពុជា
- វិភាគរកសមាសធាតុគីមី លោហៈធ្ងន់ អាសេនិច (As) បារត(Hg) សំណរ (Pb) និងកាឌីដ្យូម (Cd) នៅក្នុងទឹកអណ្តូង។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចុះពិនិត្យការងារពិសោធន៍ស្រាវជ្រាវ និងការងារផលិតកម្មគ្រាប់ពូជដំណាំស្រូវនៅខេត្តព្រះវិហារ
- ចុះត្រួតពិនិត្យ និងវាយតម្លៃការប្រើប្រាស់ពូជស្វាយចន្ទីនៅខេត្តកំពង់ចាម
- ចុះពិនិត្យការងារផលិតកម្មគ្រាប់ពូជដំណាំស្រូវ នៅខេត្តព្រះវិហារ
- ចុះពិនិត្យមើលការងារពិសោធន៍នៅខេត្តបាត់ដំបង
- ចុះប្រមូលសមាសភាពចង្រៃលើដំណាំបន្លែ និងចម្ការនៅខេត្តកំពង់ស្ពឺ កំពត និងខេត្តកែប។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២២សរុបចំនួន ៣ ១៤៤នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រផលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យា-សាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម
- រៀបចំសិក្ខាសាលាស្តីពីការគ្រប់គ្រងសម្រាម សំណល់រឹង និងសំណល់ផ្លាស្ទិកដែលរៀបចំដោយក្លឹបយុវជនប្រចាំសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងបានបើកវគ្គបណ្តុះបណ្តាលអន្តរជាតិស្តីពីការគ្រប់គ្រងសំណល់រឹង និងគោលនយោបាយដោយសហការណ៍ជាមួយសាកលវិទ្យាល័យ Hamburg Harburg ប្រទេសអាល្លឺម៉ង់ ក្រោមការឧបត្ថម្ភគម្រោង ERASMUS
- ចូលរួមក្នុងកម្មវិធី អ្នកវិទ្យាសាស្ត្រវ័យក្មេងនៃប្រទេសតំបន់ទន្លេមេគង្គក្រោមកិច្ចសហការរៀបចំដោយសាកលវិទ្យាល័យរដ្ឋអារីសូណា សហរដ្ឋអាមេរិក និងសាកលវិទ្យាល័បច្ចេកវិទ្យាហូជីមិញគាំទ្រដោយUSAID
- ជួបសំណេះសំណាល និងចែករំលែកបទពិសោធន៍គ្នារវាងដៃគូអនុវត្តគម្រោង ASMC មកពីប្រទេសកម្ពុជា

និងបង់ក្លាដេស ជាមួយប្រធានគម្រោង ASMC មកពីសហរដ្ឋអាមេរិច ដើម្បីផ្លាស់ប្តូរបទពិសោធន៍។

**១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប**

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២២ សរុបចំនួន ១ ២៦២នាក់ (ស្រី៤៩៦នាក់) លើជំនាញៈ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងស្បៀង និងភាសាអង់គ្លេស

- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូ ដើម្បីជាប្រយោជន៍សម្រាប់ការសិក្សាស្រាវជ្រាវរបស់និស្សិត និងមន្ត្រីដោយការសិក្សាស្រាវជ្រាវផ្តោតលើៈ ត្រី បង្កង បង្គា មាន់ ទា ពពែ ក្របី គោទឹកដោះ បន្លែ ផ្កា ឫស្សី ស្រូវ ចេក ស្វាយចន្ទី កាកាវ វ៉ានីឡា ស្ពៅ អាហារ ថ្នាំសត្វល្អិត និងដី

- សហប្រតិបត្តិការសំខាន់ៗរួមមានការបណ្តុះជាលិការុក្ខជាតិ អាក្វាពោនិក (ប្រព័ន្ធវារីវប្បកម្ម) ការកែច្នៃស្វាយចន្ទី ការផលិតម្សៅឫស្សី ការចិញ្ចឹមគោទឹកដោះ ការពិសោធដំណាំជប៉ុន និងការសរសេរសៀវភៅសម្រាប់ការបណ្តុះបណ្តាលរបស់វិទ្យាស្ថាន។

**១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម**

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២២ សរុបចំនួន ៥៩៤នាក់ (ស្រី២០៩នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- ពិសោធន៍លើការចម្រាញ់ប្រេងរុក្ខជាតិដូចជា ស្លឹកគ្រៃ ស្លឹកក្រូចសើច និងម្រេច

- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- បានធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប

- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

**១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

- ត្រួតពិនិត្យទូទៅការការពារ និងថែទាំចម្ការពិសោធន៍កូនកូនកៅស៊ូស៊ីដលីង និងច្បារបង្កាត់ពូជ

- ស្រង់ទិន្នន័យ បញ្ចូល និងវិភាគទិន្នន័យចម្ការពិសោធន៍កូន

- ចុះបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារនៅសហគមន៍កសិកម្មស្ថិតក្នុងខេត្តត្បូងឃ្មុំ

- ត្រួតពិនិត្យការចៀរជ័រ ការសាប្រមូលផលទឹកជ័រ ស្រង់ទិន្នន័យ បញ្ចូល និងវិភាគទិន្នន័យជ័រកៅស៊ូតាមពិធីសាពិសោធន៍គ្រប់ចម្ការពិសោធន៍

- វាស់ទំហំដើម តាមដានការលូតលាស់ចម្ការពិសោធន៍ IR.AE.19, IR.AE.20 និង IR.AE.21

- រៀបចំលាយថ្នាំរំញោច Ethephon តាមកំហាប់ខុសៗគ្នា ដើម្បីលាបរំញោចតាមពិធីសាពិសោធន៍

- ថែទាំកូនកៅស៊ូនៅថ្នាលបណ្តុះកូនឆ្នាំ២០២១-២០២២

- ត្រួតពិនិត្យការកែច្នៃកៅស៊ូសន្លឹកនៅក្នុងរោងចក្រឲ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស

- ធ្វើតេស្តកៅស៊ូសន្លឹក (RSS) ចំនួន ៦សំណាក ដើម្បីពិនិត្យគុណភាពនៃការកែច្នៃតាមស្តង់ដា CSR។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបានចំនួន ២ ១៦០ ១០១ហ.ត ស្មើនឹង៨២,៤៦% នៃផែនការចំនួន ២ ៦១៩ ៥០០ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការ

ប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសមាសភាពចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈើក្នុងតំបន់ផ្ទុះជំងឺ បទល្មើសព្រៃឈើ និងបទល្មើសជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រងការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្ម
- បន្តធ្វើការជំរុញផលិតកម្មស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩
- បន្តជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិពិសេសប្រទេសចិន
- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ
- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម
- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

### ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង
- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន
- បន្តពង្រឹង និងផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វដល់កសិករ
- ត្រៀមលក្ខណៈចុះអនុវត្តវិធានការបសុព្យាបាលកន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1)

ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) ជំងឺដុំពកស្បែកគោ ក្របី (LSD) និងជំងឺឆ្លងសត្វផ្សេងៗ

- បន្តការតាមដានស្ថានភាពជំងឺស៊ូណូសជាប្រចាំនៅតាមបណ្តារាជធានី-ខេត្ត

- ជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការអប់រំយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការប្រើប្រាស់ចំណីសត្វ និងបសុឱសថដល់អាជីវករ និងអ្នកប្រើប្រាស់

- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាមខេត្តគោលដៅ

- បន្តរៀបចំឯកសារស្តីពីអត្ថប្រយោជន៍នៃការគ្រប់គ្រងកាកសំណល់សត្វ។

## ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឱ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.គជ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានជ្រួតជ្រាបដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

## ៤ ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

## ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជីកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**